# អាជ្ញាធរអគ្គិសនីកម្ពុជា

ELECTRICITY AUTHORITY OF CAMBODIA

# ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

ELECTRICITY LAW OF THE KINGDOM OF CAMBODIA

## សេចក្តីសម្រេចកែសម្រួលលើកទី១

លើឯកសារអាជ្ញាប័ណ្ណលេខ ២៥៩ ឯអ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩ សម្រាប់ក្រុមហ៊ុន ខេមបូឌាន អេឡិកទ្រីខល អេឃ្វីបមេន ខបភើរេសិន (ស៊ី.អ៊ី.អ៊ី) ធ្វើសេវាកម្មអគ្គិសនីនៅតាមបណ្តោយផ្លូវជាតិ លេខ ៨ ចាប់ពីព្រំប្រទល់ប្រទេសកម្ពុជា-វៀតណាម មកដល់ស្រុក កំចាយមារ ស្រុកស្វាយអន្ទរ និងស្រុកពារាំង ខេត្តព្រៃវែង

សម្រាប់ការប្តូរឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណពីក្រុមហ៊ុន ស៊ី.អ៊ី.អ៊ី មកសហគ្រាស ហ្សេនីញស្ទល

## DECISION ON THE FIRST REVISION

OF THE LICENSE DOCUMENT NO.259 LDDATED DECEMBER 25, 2009 FOR CAMBODIAN ELECTRICAL EQUIPMENT CORPORATION (C.E.E) CO., LTD FOR PROVIDING ELECTRIC POWER SERVICES AT ALONG THE NATION ROAD NO.8 FROM THE BORDER OF CAMBODIA-VIETNAM TO KAMCHAY MEAR, SVAY ANTOR AND PEA RIANG DISTRICT, PREY VENG PROVINCE

FOR CHANGING THE NAME OF LICENSEE FROM C.E.E CO., LTD TO GENIINSTALL ENTERPRISE

ថ្ងៃទី ខែ ឆ្នាំ២០១០

, 2010

ព្រះរាជាណាចក្រកម្ពុជា

KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ

NATION RELIGION KING

អាជ្ញាធរអគ្គិសនីកម្ពុជា

ELECTRICITY AUTHORITY OF CAMBODIA

លេខ : -១០.អអក

# សេចក្តីសម្រេចកែសម្រួលលើកទី១ លើឯកសារអាជ្ញាប័ណ្ណលេខ ២៥៩ ឯអ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩

# DECISION ON THE THIRD REVISION OF THE LICENSE DOCUMENT No. 259 LD DATED DECEMBER 25, 2009

## អាជ្ញាធរអគ្គិសនីកម្ពុជា

## ELECTRICITY AUTHORITY OF CAMBODIA

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

- In exercise of the powers conferred by Article 7 and 35 of the Electricity Law promulgated by the Royal Decree NS/RKM/0201/03, dated 02 February 2001.

-យោងឯកសារអាជ្ញាប័ណ្ណលេខ ២៥៩ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឱ្យក្រុមហ៊ុន ស៊ី.អ៊ី.អ៊ី នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩

- In accordance with License Documents No. 259 LD issued by Electricity Authority of Cambodia on December 25, 2009 to C.E.E Co., Ltd.

-យោងពាក្យស្នើសុំផ្ទេរសិទ្ធិគ្រប់គ្រងរបស់ក្រុមហ៊ុន ស៊ី.អ៊ី.អ៊ី ទៅឱ្យសហគ្រាស ហ្សេនទីញស្តល ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១០

- In accordance with the application for changing the Licensee from C.E.E Co., Ltd to Geniinstall Enterprise, dated January 04, 2010.

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី ខែ ឆ្នាំ២០១០ ដល់ថ្ងៃទី ខែ ឆ្នាំ២០១០

- In accordance with the consultation with concerned parties and public, made from August 24, 2009 to September 30, 2009.

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី នៅថ្ងៃទី ខែ ឆ្នាំ២០១០

-In accordance with the decision of Electricity Authority of Cambodia's Session No. dated , 2010.

# សម្រេច
# DECIDES

| | |
|---|---|
| **ប្រការ១**<br>កែសម្រួលឯកសារអាជ្ញាប័ណ្ណលេខ ២៥៩ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឱ្យ **ក្រុមហ៊ុន ស៊ី.អ៊ី.អ៊ី** ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩ សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅតាមបណ្តោយផ្លូវជាតិលេខ ៨ ពីព្រំប្រទល់ប្រទេសកម្ពុជា–វៀតណាម មកដល់ស្រុកកំចាយមារ ស្រុកស្វាយអន្ទរ និងស្រុកពារាំង ខេត្តព្រៃវែង ដើម្បីប្តូរឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណពី **ក្រុមហ៊ុន ស៊ី.អ៊ី.អ៊ី** ទៅជា **សហគ្រាស ហ្សេនទីញស្ទល** (បន្ទាប់ពីនេះហៅថា "**អ្នកកាន់អាជ្ញាប័ណ្ណ**") មានទីស្នាក់ការនៅផ្ទះលេខ ២៦៩សេអ៊ី១ ផ្លូវ២៧១ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន ក្រុងភ្នំពេញ និងដែលបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ Co.7423/05P ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៥ ស្ថិតនៅក្រោមបទបញ្ញត្តិនៃក្រមពាណិជ្ជកម្ម និងរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ។ | **Article 1**<br>To revise the license document No. 259 LD on December 25, 2009 which was issued to **C.E.E Co., Ltd** for providing electricity services along the national road no. 8 from the border of Cambodia-Vietnam to Kamchay Mear, Svay Antor and Pea Riang District, Prey Veng Province is now issued to **Geniinstall Enterprise** (herein after referred to as "Licensee") located at #269CE1, St. 271, Sangkat Tuol Tompoung II, Khan Chamkar Morn, Phnom Penh City, in conformity with the commercial registration in the Kingdom of Cambodia under No. Co.7423/05P dated January 19, 2005 pursuant to the Commercial and Civil Laws. |
| **ប្រការ២**<br>ឧបសម្ព័ន្ធទី៤ "ម្ចាស់កម្មសិទ្ធិនៃអ្នកកាន់អាជ្ញាប័ណ្ណ" ចាស់នៃឯកសារអាជ្ញាប័ណ្ណលេខ ២៥៩ ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធទី៤ កែសម្រួលថ្មីដូចមានភ្ជាប់មកជាមួយ ។ | **Article 2**<br>The existing schedule 4"Ownership of licensee" of the license document No. 259 LD is replaced by the new revised schedule 4 attached herewith. |
| **ប្រការ៣**<br>ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ២៥៩ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។ | **Article 3**<br>The other contents and conditions of the license document No. 259 LD shall remain in force. |
| **ប្រការ៤**<br>សេចក្តីសម្រេចនេះ ត្រូវក្លាយជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ២៥៩ ឯអ ។ | **Article 4**<br>This decision is the part of license of the license document No. 259 LD. |
| **ប្រការ៤**<br>សេចក្តីសម្រេចនេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ | **Article 4**<br>The decision shall come into force from the date of signing. |
| **ប្រការ៥**<br>អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណ លេខ ២៥៩ ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណលេខ ២៥៩ ឯអ ដែលតម្កល់មានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។ | **Article 5**<br>The licensee shall send this decision to deposit additionally at the places, where the license document No. 259 LD has been deposited in order that the deposited license document No. 259 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០១០

Phnom Penh, , 2010

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF ELECTRICITY AUTHORITY OF CAMBODIA

# ឧបសម្ព័ន្ធទី៤
# ម្ចាស់កម្មសិទ្ធិនៃអ្នកកាន់អាជ្ញាប័ណ្ណ
## SCHEDULE 4
## OWNERSHIP OF LICENSEE

| | |
|---|---|
| ១- **សហគ្រាស ហេង្សនីញស្មល** គឺជាសហគ្រាសឯកបុគ្គល ដែលមានលោក **យីវ ញៀន** ជាឯកកម្មសិទ្ធិករ ។ | 1. Mr. **Yiv Nhean** is the single owner of the **Geniinstall Enterprise**. |
| ២- យោងតាមមាត្រា ៤៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ម្ចាស់កម្មសិទ្ធិដែលបានចុះបញ្ជីដូចខាងលើ ពុំអាចមានភាគហ៊ុន ឬមានផលប្រយោជន៍ហិរញ្ញវត្ថុផ្ទាល់ ជាមួយអ្នកកាន់អាជ្ញាប័ណ្ណផ្សេងទៀត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍ពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ ក្នុងករណីជាក់លាក់ណាមួយដើម្បីជាផលប្រយោជន៍សាធារណៈ អាជ្ញាធរអគ្គិសនីកម្ពុជាអាចចេញសេចក្តីសម្រេចអនុញ្ញាតឱ្យបាន ។ | 2. Refer to Article 45 of the Electricity Law of the Kingdom of Cambodia, the above registered owners shall not own shares in or have any other direct financial interests in any other licensee without written permission from EAC. EAC may permit in specific cases in public interest. |